# តារាងស្តីពីព័ត៌មានរបស់គម្រោង

លេខPIP : 1099

( សម្រាប់បំពេញដោយក្រសួងផែនការ )

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

ផ្នែក ក

*( ត្រូវបំពេញគ្រប់ចំណុចទាំងអស់ )*

១. ឈ្មោះគម្រោង : គម្រោងកែលម្អការចិញ្ចឹមសត្វ លើកកម្ពស់សុខភាពសត្វ និងសុខភាពសាធារណៈបសុព្យាបាល

២. កាលបរិច្ឆេទគម្រោង

| | |
|---|---|
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | 01/01/21 |
| កាលបរិច្ឆេទបញ្ចប់គម្រោង | 31/12/23 |

៣. ចំណាយគម្រោងសរុប $10,509,400

៤. ស្ថាប័នទទួលខុសត្រូវ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

| | |
|---|---|
| RESPONSIBLE UNIT | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| អង្គភាពទទួលខុសត្រូវ | អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ |

៥. ស្ថានភាពគម្រោង គម្រោងដែលបានលុបចោល

ព័ត៌មានលម្អិតអំពីគម្រោង

៦. ប្រភេទគម្រោង ៖ គម្រោងវិនិយោគជាទុន

៧. ប្រភពហិរញ្ញប្បទាន៖ ស្វែងរកម្ចាស់ជំនួយ

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

មុំទី២- ការលើកស្ទួយសហគ្រាសធុនមីក្រូ តូច និងមធ្យម ធុរកិច្ចថ្មី សហគ្រិនភាព និងការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

គម្រោងនេះនឹងចូលរួមក្នុងការលើកស្ទួយផលិតកម្មសត្វ និងសុខភាពសត្វ តាមរយៈការកែលម្អពូជគោ ដោយការបង្កាត់ពូជ កាត់បន្ថយអត្រាសត្វឈឺ បង្កើនគុណភាពចំណីអាហារ អាហារូបត្ថម្ភ។

## ១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាដែរឬទេ ? មិនគាំទ្រ

**១១. វិស័យ** ( សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

កសិកម្ម និងការគ្រប់គ្រងដីធ្លី Livestock

**១២. ទីតាំងអនុវត្តគម្រោង** ( ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង )

ពោធិ៍សាត់, រាជធានីភ្នំពេញ,

១៣. គោលបំណងរបស់គម្រោង (ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង)

គម្រោងនេះត្រូវបានរៀបចំឡើងក្នុងគោលបំណង៖

-លើកកម្ពស់ការចិញ្ចឹមសត្វ តាមរយៈការបង្កើតមជ្ឈមណ្ឌលបង្កាត់សិប្បនិម្មិតដើម្បីកែលម្អពូជសត្វ និងការបង្កាត់ ពូជគោ

-កាត់បន្ថយអត្រាសត្វឈឺ តាមរយៈការបង្កើតមន្ទីរពិសោធន៍ផលិតដែលមានសមត្ថភាពផលិតថ្នាំការពារជម្ងឺសារទឹក គោ ក្របីប្រកបដោយគុណភាពសំរាប់ចែកចាយនៅទូទាំងប្រទេស

-លោកកម្ពស់សុវត្ថិភាពចំណីអាហារដោយអនុលោមតាមគោលការណ៍គុណភាពសាច់ និងវិធានអនាម័យខ្ពស់ គោរពតាមសុខុមាលភាពសត្វ តាមរយៈការកែលម្អសត្តឃាតដ្ឋានឱ្យមានកំរិតស្តង់ដា

១៤. ការពិពណ៌នាអំពីគម្រោង (ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង)

អនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វបានចូលរួមយ៉ាងសកម្មក្នុងការបង្កើតការងារ សន្តិសុខស្បៀង អាហារូបត្ថម្ភ កំណើនសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា។ ដើម្បីឱ្យការរួមចំណែកនេះកាន់តែមានប្រសិទ្ធភាព

គម្រោងត្រូវចែកជាបីផ្នែកសំខាន់ៗគឺ៖

-សាងសង់ស្ថានីយបង្កាត់ពូជសិប្បនិម្មិត

-សាងសង់ស្ថានីយពិសោធន៍ផលិតថ្នាំការពារជម្ងឺសត្វ

-កែលម្អសត្តឃាតដ្ឋាន អនាម័យសត្វ សាច់ និងផលិតផលសត្វ

១៥. យុត្តិកម្មលើគម្រោង (បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស)

យោងតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៩-២០២៣ បានកំណត់ផលិតផលសាច់សត្វសរុបកើនដល់២៧០ពាន់តោន នៅឆ្នាំ២០២៣។ ដើម្បីសម្រេចឱ្យបាននូវសូចនាករនេះតម្រូវឱ្យការចិញ្ចឹមត្រូវតែមានការកែលម្អទាំងបច្ចេកទេស និងពូជពូជសត្វចិញ្ចឹមល្អៗជានាបាននូវគុណភាពសាច់ និងកាត់បន្ថយបានទាំងជម្ងឺសត្វ។

១៦. ផលប្រយោជន៍របស់គម្រោង (រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង)

គម្រោងនេះនឹងផ្តល់អត្ថប្រយោជន៍ដោយផ្ទាល់យ៉ាងច្រើន ដល់កសិករចិញ្ចឹមសត្វ ម្ចាស់សត្តឃាតដ្ឋាន មន្ត្រីបច្ចេកនៃការិយាល័យផលិតកម្ម និងបសុព្យាបាលរដ្ឋអំណាចមូលដ្ឋាន មន្ត្រីអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ និអ្នកពាក់ពន្ធ័។

១៧. ការសិក្សាសមិទ្ធិលទ្ធភាព

| | |
|---|---|
| តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? | **គ្មាន** |
| ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? | **មិនទានចាប់ផ្តើម** |

១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម (ពិពណ៌សង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

គម្រោងនេះនឹងចូលរួមយ៉ាងសកម្មដល់ការកាត់បន្ថយភាពក្រីក្ររបស់ពលរដ្ឋកម្ពុជាទាំងអស់ តាមរយៈការផ្តល់នូវបច្ចេកទេសចិញ្ចឹមសត្វសមស្រប គោរពតាមគោលការណ៍ចិញ្ចឹមសត្វល្អ(GAHP) មានលក្ខណៈទំនើប ជាមួយពូជសត្វមានល្អៗមានផលិតភាពខ្ពស់ ព្រមទាំងការផ្គត់ផ្គង់សាច់ ផលិតផលសត្វប្រកបដោយដោយអនាម័យ និងគុណភាពខ្ពស់។

១៩. ការប្រែប្រួល អាកាសធាតុ

| | |
|---|---|
| ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? | **មាន** |
| ប្រសិនបើទាក់ទងនឹងការប្រែប្រួលអាកាស ធាតុ សូមជ្រើសរើស | **ទាំងពីរ** |

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុ |
|---|---|---|
| **១៨. ជីវភាពរស់នៅ (ទូទៅ)** | 0 | **មិនភាពទាក់ទង** |

**២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ**

តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យនិងគ្រោះមហន្តរាយដែរឬទេ? **មាន**

ប្រសិនបើ ទាក់ទងនឹងការកាត់បន្ថយហានិភ័យនិងគ្រោះមហន្តរាយ សូមជ្រើសរើស **ការត្រៀម**

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

គម្រោងនេះនឹងរួមចំណែកដល់ការលើកកម្ពស់តួនាទីបុរស និងស្ត្រីក្នុងការបំពេញតួនាទីរបស់ពួកគេ តាមកំរិតបច្ចេក ទេស និងតួនាទីក្នុងរចនាដែលមានស្រាប់របស់ស្ថាប័ន។ មន្ត្រីបច្ចេកទេសជាស្ត្រីដែលកំពុងបំរើការងារផ្នែកមន្ទីរពិសោធន៍នៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ និងត្រូវលើកទឹកចិត្ត ឱ្យចូលរួមក្នុងអនុវត្តគម្រោងនេះ។

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ជាអង្គភាពជំនាញ ដែលមានតួនាទីជាសេនាធិការឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទទួលខុសត្រូវលើការងារសុខភាពសត្វ និងផលិតកម្មសត្វ ហើយមានភារៈកិច្ចសំខាន់ៗជាច្រើនត្រូវបំពេញស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលនិតិកាលទី៦នៃរដ្ឋសភា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យកសិកម្ម ២០១៩-២០២៣។ ដើម្បីអនុវត្តភារកិច្ចបានទទួលជោគជ័យ អគ្គនាយកដ្ឋានមានរចនាសម្ព័ន្ធគ្រប់គ្រងត្រឹមត្រូវ និងអ្នកបច្ចេកទេសគ្រប់កំរិតដែលមានបទពិសោធន៍។ បុគ្គលិកទាំងអស់នឹងត្រូវចូលរួមអនុវត្តគម្រោងនេះទៅតាមជំនាញរបស់ខ្លួន។

២៣. [illegible] គម្រោងនិងបង្ហាញអំពីភាពប្រឈមនានា ដែល បណ្តាលឲ្យ[illegible]

កំពង់តែស្វែងរកថវិកាដើម្បីដំណើការគម្រោង

**២៤. អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

1

**២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

កំពុងស្វែងរកជំនួយថវិកាគាំទ្រ និងពិភាក្សាជាមួយដៃគូ

## ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2022 | | 2023 | 2024 | 2025 | 2026 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2024-2026 | ចរន្ត |
| **ចំណាយប្រតិបត្តិ** | 0.0 | 0.0 | 0.0 | 26.0 | 13.0 | 14.0 | 53.0 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សម្ភារៈនិងរដ្ឋបាល | 0.0 | 0.0 | 0.0 | 23.0 | 10.0 | 10.0 | 43.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 3.0 | 3.0 | 4.0 | 10.0 | 0.0 |
| | | | | | | | | |
| **ចំណាយមូលធន** | 0.0 | 0.0 | 0.0 | 2,181.4 | 3,791.0 | 4,484.0 | 10,456.4 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 0.0 | 0.0 | 0.0 | 1,700.0 | 2,687.5 | 3,500.0 | 7,887.5 | 0.0 |
| សេវាទីប្រឹក្សា | 0.0 | 0.0 | 0.0 | 300.0 | 100.0 | 50.0 | 450.0 | 0.0 |
| ទព្វសម្ភារៈ | 0.0 | 0.0 | 0.0 | 115.4 | 950.0 | 890.0 | 1,955.4 | 0.0 |
| ការបណ្តុះបណ្តាល | 0.0 | 0.0 | 0.0 | 63.0 | 50.0 | 40.0 | 153.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 3.0 | 3.5 | 4.0 | 10.5 | 0.0 |
| | | | | | | | | |
| **ចំណាយសរុប** | 0.0 | 0.0 | 0.0 | 2,207.4 | 3,804.0 | 4,498.0 | 10,509.4 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2022 | | 2023 | 2024 | 2025 | 2026 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2024-2026 | |
| | | | | | | | | |
| ចំណូលពីគម្រោង | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ថវិកាជាតិ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម | 0.0 | 0.0 | 0.0 | 2,207.4 | 3,804.0 | 4,498.0 | 10,509.4 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: